# ស្ថានទូតជប៉ុន
# ប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសពត៌មាន

លេខ៖ 11 PR-18/EoJ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៨

## ប្រទេសជប៉ុនផ្តល់ថវិកាសរុបចំនួន ៣៤២,៦៦៣ដុល្លារអាមេរិក សម្រាប់កែលំអបរិស្ថាននៃការសិក្សាសំរាប់កុមារពិការ និង សាងសង់អគារមន្ទីរពេទ្យ

រដ្ឋាភិបាលជប៉ុន បានឯកភាពផ្តល់ថវិកាសរុបចំនួន ៣៤២,៦៦៣ ដុល្លារអាមេរិក ដល់អង្គភាពទទួលជំនួយចំនួន៤ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងអង្គភាពទទួលជំនួយទាំងបួន សម្រាប់គម្រោងដូចតទៅ៖

### ១. គម្រោងសាងសង់ភូមិសហគមន៍សាមគ្គីធម៌ម៉ារីស្តកម្ពុជា ខេត្តកណ្តាល (ថវិកាចំនួន ៧២,១៧៩ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយ៖ សាមគ្គីធម៌ម៉ារីស្តកម្ពុជា

គម្រោងនេះនឹងសាងសង់អគារសិក្សាថ្មីមួយខ្នងដែលមាន៣បន្ទប់ និង ផ្លូវតភ្ជាប់ (ប្រវែង២២៥ម) ក្នុងភូមិសហគមន៍សាមគ្គីធម៌ម៉ារីស្តកម្ពុជា ក្នុងខេត្តកណ្តាល ជាកន្លែងដែលអង្គការជួយឧបថម្ភដល់កុមារ និងយុវជនដែលមានពិការភាព។ គំរោងនេះនឹងផ្តល់នូវឱកាសដល់សិស្សប្រមាណ៨០នាក់ជារៀងរាល់ឆ្នាំអោយទទួលបាននូវការសិក្សាក្នុងបរិស្ថានដែលល្អជាងមុន ព្រមទាំងផ្តល់អោយបុគ្គលិក លោកគ្រូ អ្នកគ្រូ និង សិស្សានុសិស្ស នូវភាពងាយស្រួល និង សុវត្ថិភាពក្នុងការធ្វើដំណើរពីអគារមួយទៅអគារមួយផងដែរ។

### ២ .គម្រោងសាងសង់អគារផ្នែកជំងឺទូទៅនិងជំងឺកុមារក្នុងមន្ទីរពេទ្យបង្អែកបាទី ខេត្តតាកែវ (ថវិកាចំនួន ៩០,៧១២ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយ៖ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបាទី ខេត្តតាកែវ

គម្រោងនេះនឹងសាងសង់អគារផ្នែកជំងឺទូទៅនិងជំងឺកុមារថ្មីមួយក្នុងមន្ទីរពេទ្យបង្អែកបាទី ខេត្តតាកែវ ដោយហេតុមានអ្នកជំងឺមកសំរាកព្យាបាលយ៉ាងណែនតាន់តាប់ពេកក្នុងអគារទាំងពីរនេះ។ យើងរំពឹងថាជារៀងរាល់ឆ្នាំ

នឹងមានអ្នកជំងឺសំរាកព្យាបាលផ្នែកជំងឺទូទៅប្រមាណ២,១០០នាក់ និង ៥៥០នាក់ផ្នែកជំងឺកុមារអាចទទួលបាននូវសេវាសុខាភិបាលក្នុងបរិស្ថានវេជ្ជសាស្ត្រដែលកាន់តែល្អប្រសើរជាងមុន។

**៣ .<u>គម្រោងសាងសង់អគារជំងឺទូទៅក្នុងមន្ទីរពេទ្យបង្អែកកោះញែក ខេត្តមណ្ឌលគិរី</u>**

**<u>(ថវិកាចំនួន ៨៩,៧០០ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយៈ មន្ទីរសុខាភិបាលខេត្តមណ្ឌលគិរី</u>

គម្រោងនេះនឹងសាងសង់អគារជំងឺទូទៅថ្មីមួយក្នុងមន្ទីរពេទ្យបង្អែកកោះញែក ខេត្តមណ្ឌលគិរី ដែលក្នុងពេលបច្ចុប្បន្នមន្ទីរពេទ្យមានតែអគារសំខាន់ៗចំនួនពីរតែប៉ុណ្ណោះ។ គម្រោងមួយនេះនឹងជួយកែលំអបរិស្ថានវេជ្ជសាស្ត្រ និង លើកកំពស់សមត្ថភាពផ្នែកផ្សេងៗទៀតរបស់មន្ទីរពេទ្យ។ យើងរំពឹងថាប្រជាជនប្រមាណ១៨,០០០នាក់នឹងអាចទទួលបានសេវា សុខាភិបាលដែលមានភាពល្អប្រសើរជាងមុន។

**៤ .<u>គម្រោងសាងសង់អគារសង្គ្រោះបន្ទាន់ក្នុងមន្ទីរពេទ្យបង្អែកបារាយណ៍-សន្ទុក</u>**

**<u>(ថវិកាចំនួន ៩០ ០៧២,ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយៈ មន្ទីរសុខាភិបាលខេត្តកំពង់ធំ</u>

គម្រោងនេះនឹងសាងសង់អគារសង្គ្រោះបន្ទាន់ថ្មីមួយក្នុងមន្ទីរពេទ្យបង្អែកបារាយណ៍-សន្ទុកខេត្តកំពង់ធំ។ គម្រោងនេះនឹងជួយកែលំអបរិស្ថានវេជ្ជសាស្ត្ររបស់អគារសង្គ្រោះបន្ទាន់ ដែលក្នុងពេលបច្ចុប្បន្ននេះមានតែបន្ទប់តូចៗចំនួនពីរសំរាប់ផ្តល់ការព្យាបាលតែបុណ្ណោះ។ យើងរំពឹងថាជារៀងរាល់ឆ្នាំនឹងមានអ្នកជំងឺប្រមាណ១,១០០ នាក់អាចទទួលបានសេវាសង្គ្រោះបន្ទាន់ ជាមួយនឹងការមើលថែទាំយ៉ាងយកចិត្តទុកដាក់ព្រមជាមួយនឹងការព្យាបាលបន្ទាន់ក្នុងបរិស្ថានដែលសមស្របមួយ។

*ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជាៈ ភាពក្រីក្រ និងភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង ៥៧ លានដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន ៥៨៦ គម្រោងនៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារៈ ០២៣-២១៤-៣៣០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*